


## ធុងសំរាមទូទៅ

ធុងសំរាមគម្របក្រហមគឺសម្រាប់វត្ថុកខ្វក់
បែកបាក់ និងមិនអាចកែច្នៃឡើងវិញបាន។



សម្លៀកបំពាក់
និងស្បែកជើងចាស់



ស្រោមដៃ
និងម៉ាស់មុខ



ប៉ូលីស្ទីរីន



ធូលីម៉ាស៊ីនបូម



បំពង់ និងបំពង់ PVC



ចានឆ្នាំង
និងប្លាស្ទិកទន់ទាំងអស់

សំរាមទាំងអស់នេះនឹងត្រូវបានកប់ក្នុងកន្លែងចាក់សំរាម។

ប្រសិនបើអ្នកមានសំណួរណាមួយអំពីសេវាកម្មធុងសំរាមរបស់អ្នក សូម
ទូរសព្ទទៅក្រុមសេវាកម្មអតិថិជន NAWMA តាមលេខ 8259 2100។

# NAWMA
# ការណែនាំអំពីធុងសំរាមនៅតាមចិញ្ចើមថ្នល់

ការណែនាំនេះពន្យល់អំពីរបៀបបោះចោលវត្ថុប្រើប្រាស់ក្នុង
ផ្ទះរបស់អ្នកឱ្យបានត្រឹមត្រូវ។




## ធុងវត្ថុកែច្នៃឡើងវិញតាមផ្ទះ

ប្រើធុងវត្ថុកែច្នៃឡើងវិញតាមផ្ទះសម្រាប់វត្ថុទាំងនេះ។
កម្មកររបស់យើងនឹងតម្រៀបវត្ថុទាំងនេះទៅតាមប្រភេទ
ដោយដៃ ដូច្នេះសូមប្រាកដថាវាស្អាត។




ដែកថែប




ក្រដាស និងក្រដាសកាតុង




អាលុយមីញ៉ូម



កញ្ចក់



ប្លាស្ទិករឹង



មិនត្រូវមានប្លាស្ទិកទន់

វត្ថុចាស់ៗរបស់អ្នកនឹងត្រូវបានកែច្នៃទៅជាផលិតផលថ្មីៗ ដើម្បីប្រើប្រាស់ម្តងទៀត។

City of Salisbury · City of Playford · Gawler · NAWMA Northern Adelaide Waste Management Authority · NAWMA Northern Adelaide Waste Management Authority




# ធុងកាកសំណល់អាហារ និងសារធាតុសរីរាង្គពីសួនច្បារ (FOGO)

ប្រើធុង FOGO សម្រាប់កាកសំណល់អាហារ
និងកម្ទេចកំណាត់រុក្ខជាតិទាំងអស់។

សូម្បីតែវត្ថុដូចជាចម្រៀកក្រដាស ក្រដាសអនាម័យដែលប្រើរួច កាកសំណល់
សត្វចិញ្ចឹម និងអាហារឆ្អិន ក៏អាចបោះចោលទៅក្នុងធុងសំរាមនេះបានដែរ។



ចម្រៀកក្រដាស



ប្រអប់នំភីហ្សាប្រឡាក់ខ្លាញ់
និងកាកសំណល់អាហារ



សក់មនុស្ស
និងរោមសត្វចិញ្ចឹម



ស្លឹកឈើ កំណាត់ឈើ
និងមែកឈើ
(កំណាត់អង្កត់ផ្ចិត 100មម)



ថង់តែ
និងកាកកាហ្វេ



ក្រដាសអនាម័យ
និងក្រដាសជូត

វត្ថុទាំងនេះនឹងត្រូវបានប្រែក្លាយទៅជាជីកំប៉ុស
ដើម្បីប្រើប្រាស់ក្នុងកសិដ្ឋាន និងសួនច្បារ។

# ការប្រើប្រាស់ធុងកាកសំណល់ផ្ទះបាយ (Kitchen Caddy) របស់អ្នក



នៅពេលអ្នកបញ្ជាធុងសំរាម FOGO ពី NAWMA អ្នកនឹងទទួលបាន
**ធុងកាកសំណល់ផ្ទះបាយដែលមានខ្យល់ចេញចូលមួយដោយឥតគិតថ្លៃ
និងថង់ដែលអាចក្លាយជាជីកំប៉ុសមួយដុំ** ដើម្បីប្រមូលកាកសំណល់អាហាររបស់អ្នក។

ប្រើថង់ដែលអាចក្លាយជាជីកំប៉ុសដើម្បី
ដាក់ទ្រាប់ធុងកាកសំ
ណល់ផ្ទះបាយរបស់អ្នក
ហើយបន្ទាប់មកចាប់ផ្តើមបំពេញវា
ជាមួយកាកសំណល់អាហារ។



នៅពេលថង់ដែលអាចក្លាយជាជីកំប៉ុសពេញ
ត្រូវដាក់វាចូលទៅក្នុងធុង FOGO។
អ្នកនឹងត្រូវផ្លាស់ប្តូរថង់រៀងរាល់
2-3 ថ្ងៃម្តង។




អ្នកអាចទិញ
ថង់ដែលអាចក្លាយជាជីកំប៉ុសបន្ថែមទៀតពី
ផ្សារទំនើប។ រកមើលស្លាកសញ្ញា AS 4736
ដែលបោះពុម្ពនៅលើថង់
ព្រោះថង់ពិសេសទាំងនេះនឹងបំបែក
ទៅជាជីកំប៉ុស។

អ្នកក៏អាចរុំ
កាកសំណល់អាហាររបស់អ្នកនៅក្នុងក្រដាស
សារព័ត៌មាន
ឬបោះចោលវាដោយផ្ទាល់ទៅក្នុងធុង
FOGO បានផងដែរ។

AS 4736

ស្លាកសញ្ញាដែលអាចក្លាយជាជីកំប៉ុស




រកមើលស្លាកសញ្ញាថង់ដែល
អាចក្លាយជាជីកំប៉ុស
ហើយប្រើថង់នេះ

**សូមចងចាំ៖**
**កុំប្រើថង់ប្លាស្ទិកធម្មតាក្នុងធុងកាកសំណល់ផ្ទះបាយរបស់អ្នក។**

**ទូរសព្ទ៖ 8259 2100**
**nawma.sa.gov.au**

NAWMA
NORTHERN ADELAIDE WASTE MANAGEMENT AUTHORITY